Disability Rights California
California's Protection & Advocacy System
Toll-Free (800)776-5746
www.disabilityrightsca.org

MENTAL HEALTH SERVICES ACT
PROPOSITION 63
CALIFORNIA
WELLNESS • RECOVERY • RESILIENCE

# សិទ្ធិ របស់អ្នកជួល(ភតិកៈ) ដែលមានបញ្ហាសុខភាពផ្លូវចិត្ត ចំពោះសេវាកម្ម ឬ ការចិញ្ចឹមសត្វជំនួយទឹកចិត្ត

### ចំពោះម្ចាស់ផ្ទះ(ភតិសន្យា) & ក្រុមហ៊ុនផ្តល់សេវាកម្មផ្ទះសម្បែងស្នាក់នៅផ្សេងៗទៀត

## 1. តើអ្វីទៅជា "ដំណោះស្រាយសមស្រប" ក្នុងបញ្ហាផ្ទះសម្បែង?

មនុស្សពិការម្នាក់នៅរដ្ឋកាលីហ្វ័រញ៉ា មានសិទ្ធិស្ថិតក្រោមច្បាប់រដ្ឋ និង សហព័ន្ធ[1] ដើម្បីរួចពីបញ្ហាការរើសអើងក្នុងបញ្ហាការលក់ ឬ ជួលផ្ទះសម្បែងស្នាក់នៅ។ សិទ្ធិនេះមានន័យថា ម្ចាស់ផ្ទះ(ភតិសន្យា)[2], ម្ចាស់ ឬ ក្រុមហ៊ុនផ្តល់សេវាកម្មផ្ទះសម្បែងរស់នៅ, ឬ ក្រុមហ៊ុនអចលនៈទ្រព្យ មិនអាចនឹងបដិសេធជួល ឬ លក់ឲ្យអ្នកណាម្នាក់ ឬ ចូលរួមចំណែកពាក់ព័ន្ធនៅក្នុងប្រភេទផ្សេងទៀតនៃបញ្ហាការរើសអើស ដោយសារតែបុគ្គលនោះមានបញ្ហាសុខភាពផ្លូវចិត្ត ឬ ពិការភាពរាងកាយនោះទេ។ ក្រុមហ៊ុនផ្តល់សេវាកម្មផ្ទះសម្បែងមួយ ក៏ត្រូវតែផ្តល់ "ដំណោះស្រាយសមស្របនានា" ដល់ភតិកៈ និង ម្ចាស់សំណើផ្ទះសម្បែងស្នាក់នៅដែលមានបញ្ហាសុខភាពផ្លូវចិត្តផងដែរ។ នេះមានន័យថា ក្រុមហ៊ុនផ្តល់សេវាកម្មផ្ទះសម្បែងស្នាក់នៅ ត្រូវតែប្រកាន់យកនូវដំណាក់កាលសមស្របនានា ដើម្បីផ្លាស់ប្តូរវិធានច្បាប់ គោលការណ៍ ឬ ការអនុវត្តន៍នានា ដើម្បីអនុញ្ញាតឲ្យមនុស្សមានបញ្ហាសុខភាពផ្លូវចិត្តម្នាក់ប្រើ ឬ រីករាយចំពោះបញ្ហាផ្ទះសម្បែងស្នាក់នៅ។

*សម្រាប់ព័ត៍មានបន្ថែមអំពីសិទ្ធិជនពិការចំពោះដំណោះស្រាយសមស្របក្នុងបញ្ហាផ្ទះសម្បែងស្នាក់នៅ ចូរមើលទំព័រព័ត៍មានសំខាន់ៗអំពីសិទ្ធិជនពិការនៅរដ្ឋកាលីហ្វ័រញ៉ា: ក្រុមអ្នកជួលផ្ទះ (ភតិកៈ) ដែលមានបញ្ហាសុខភាពផ្លូវចិត្ត: សិទ្ធិចំពោះដំណោះស្រាយសមស្របនានាក្នុងបញ្ហាផ្ទះសម្បែង។*

---

[1] ច្បាប់ការងារត្រឹមត្រូវ និង ច្បាប់ស្តីពីបញ្ហាផ្ទះសម្បែងស្នាក់នៅ ប្រើពាក្យថា៖ "ពិការ" ជំនួសឲ្យ "អសមត្ថភាព" តែអត្ថន័យគឺដូចគ្នា។

[2] ច្បាប់ទាំងនេះ អនុវត្តចំពោះម្ចាស់ផ្ទះ(ភតិសន្យា)ឯកជនទាំងអស់ វៀរលែងតែភតិសន្យាទាំងឡាយណាដែលមានផ្ទះនៅដាច់តែមួយគ្រួសារ រស់នៅក្នុងផ្ទះនោះ និង ជួលឲ្យតែបន្ទប់មួយឲ្យទៅអ្នកជួលផ្ទះ និង ទិញឥវ៉ាន់ពីម្ចាស់ផ្ទះប៉ុណ្ណោះ។

## 2. តើសត្វចិញ្ចឹមជំនួយទឹកចិត្ត និង សត្វបម្រើមានភាពខុសគ្នាយ៉ាងដូចម្តេច?

សត្វបម្រើមួយក្បាល គឺជាសត្វដែលមានការបង្រៀនឲ្យចេះធ្វើកិច្ចការជាក់លាក់នានា ដែលជួយដល់ជនពិការម្នាក់។ ឧទាហរណ៍ ឆ្កែមួយក្បាលទទួលបានការបង្រៀនឲ្យចេះស្គាល់នៅពេលដែលម្ចាស់កំពុងតែមានបញ្ហារោគផ្លូវចិត្ត និងឆ្លើយតបតាមវិធីមួយ ដែលជួយថែរក្សាមនុស្សឲ្យមានសុវត្ថិភាព រហូតដល់បញ្ហារោគនេះបានថមថយចុះ។ សត្វ (ឬ "សហការី") ជំនួយផ្លូវចិត្តមួយក្បាល គឺជាសត្វមួយ ដែលផ្តល់នូវភាពងាយស្រួលចំពោះមនុស្សម្នាក់ ដែលមានបញ្ហាសុខភាពផ្លូវចិត្ត ដោយមិនចាំបាច់មានការបង្រៀនឲ្យចេះធ្វើកិច្ចការជាក់លាក់នានា ដើម្បីជួយលដល់មនុស្សនោះទេ។

## 3. តើខ្ញុំចាំបាច់ត្រូវបដិសេធវិធានច្បាប់ហាមចិញ្ចឹមសត្វ ដើម្បីអនុញ្ញាតឲ្យមានសត្វជំនួយទឹកចិត្ត ឬ បម្រើរបស់ភតិកៈម្នាក់ ដើម្បីរស់នៅក្នុងផ្ទះបាននោះដែរឬទេ?

ក្នុងនាមជាម្ចាស់ផ្ទះ(ភតិសន្យា)ម្នាក់ ឬ ក្រុមហ៊ុនផ្តល់សេវាកម្មផ្ទះសម្បែងស្នាក់នៅផ្សេងទៀត អ្នកអាចនឹងមានតម្រូវការចាំបាច់បដិសេធ ឬ បោះបង់វិធានច្បាប់ "ហាមចិញ្ចឹមសត្វ" ដែលជាដំណោះស្រាយសមស្របមួយ ដើម្បីអនុញ្ញាតិឲ្យជនពិការម្នាក់រស់នៅដោយមានសត្វបម្រើ ឬ ជំនួយទឹកចិត្តមួយបាន។[3] លើសពីនេះ ដំណោះស្រាយនេះនឹងមិនទទួលបានការគិតពិចារណាថាសមស្របទេ បើសត្វនោះនឹង: ចោទជាបញ្ហាគម្រាមកម្ហែងដល់ភតិកៈផ្សេងៗទៀត បណ្តាលឲ្យមានអន្តរាយជាក់ស្តែងធំៗដល់ទ្រព្យសម្បត្តិ នាំឲ្យមានបន្ទុកផ្នែកហិរញ្ញវត្ថុ ឬ រដ្ឋបាលច្រើនហួសហេតុ ឬ ប្តូរជាមូលដ្ឋាននូវសភាពដើមនៃសេវាកម្មនានា ដែលភតិសន្យាផ្តល់ឲ្យ។ ម្ចាស់សត្វបម្រើ ឬ ជំនួយទឹកចិត្ត មានទំនួលខុសត្រូវចំពោះការមើលថែសត្វនោះ និង ការធានាឲ្យបានថា សត្វនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ត្រួតពិនិត្យសត្វរបស់រដ្ឋ និង តាមមូលដ្ឋាន ហើយមិនមានគ្រោះថ្នាក់ ឬ រំខានដល់សហគមន៍។

## 4. តើខ្ញុំត្រូវឆ្លើយតបទៅនឹងសំណើមួយ ដែលសុំឲ្យបដិសេធ ឬ បោះបង់វិធានច្បាប់ហាមចិញ្ចឹមសត្វ ដើម្បីអនុញ្ញាតមានចិញ្ចឹមសត្វបម្រើ ឬ សត្វជំនួយទឹកចិត្តយ៉ាងដូចម្តេច?

សំណើសុំចិញ្ចឹមសត្វបម្រើ ឬ ជំនួយទឹកចិត្ត ត្រូវកំណត់ប្រភេទមនុស្ស ដែលកំពុងធ្វើសំណើថាជាមនុស្សម្នាក់ដែលពិការ ហើយពន្យល់ប្រាប់អំពីមូលហេតុ ដែលមនុស្សនោះចាំបាច់ត្រូវការឲ្យមានសត្វរស់នៅក្នុងផ្ទះ ដោយសារតែបញ្ហាពិការភាពរបស់មនុស្សនោះ។ អ្នកត្រូវឆ្លើយតបទៅនឹងសំណើនោះឲ្យតាមឆាប់ៗតាមដែលអាចធ្វើទៅបាន។ បើអ្នកមិនអាចឆ្លើយតបមុនកាលបរិច្ឆេទ ដែលបុគ្គលនោះបានស្នើសុំទេនោះ អ្នកត្រូវពន្យល់ប្រាប់ថា អ្នកចាំបាច់ត្រូវការពេលវេលាបន្ថែមទៀត និង ឲ្យមនុស្សដឹងពីពេលវេលា ដែលរំពឹងនឹងទទួលបានចម្លើយតបមួយ។ បើសំណើនោះមិនច្បាស់លាស់ទេនោះ អ្នកអាចស្នើសុំបំណកស្រាយពន្យល់មួយបាន។ លើសពីនេះ អ្នកអាចនឹងស្នើសុំលិខិតបញ្ជាក់មួយច្បាប់ពីវេជ្ជបណ្ឌិត ឬ គ្រូពេទ្យជំនាញផ្សេងទៀត ដែលបញ្ជាក់ថាមនុស្សនោះមានពិការភាពពិតប្រាកដមែន ហើយនិងលើកឡើងអំពីមូលហេតុ

---

[3] នៅឆ្នាំ 2011បញ្ញត្តិច្បាប់នានា ដែលស្ថិតក្រោមច្បាប់ការពារជនពិការអាមេរិកាំង បានចូលជាធរមាន ដែលតម្រូវឲ្យភោជនីយដ្ឋាន ហាងទំនិញ និង ក្រុមហ៊ុនផ្សេងៗទៀត អនុញ្ញាតឲ្យមានតែឆ្កែបម្រើ និង មិនមានសត្វជាសហការី ឬ ប្រភេទសត្វបម្រើផ្សេងៗទៀតទេ ដែលជាដំណោះស្រាយសមស្របចំពោះអតិថិជនពិការ។ យ៉ាងណាមិញ បញ្ញត្តិច្បាប់ទាំងនេះមិនប៉ះពាល់ដល់សិទ្ធិភតិកៈ ដែលជាជនពិការចំពោះសិទ្ធិមានសត្វបម្រើលើសពីសត្វឆ្កែ ឬ សត្វជាសហការី (ចិញ្ចឹមបានជាគ្នា) នៅក្នុងផ្ទះស្នាក់នៅទេ។

ដែលគាត់ចាំបាច់ត្រូវការចិញ្ចឹមសត្វបម្រើ ឬ ជំនួយទឹកចិត្តឲ្យរស់នៅក្នុងផ្ទះ។ យ៉ាងណាមិញ អ្នកនឹងមិនអាចស្នើសុំសំណៅកំណត់ហេតុពេទ្យ ការវាយតម្លៃជាក់លាក់មួយច្បាប់ ឬ ការអនុញ្ញាតឲ្យនិយាយជាមួយនឹងគ្រូពេទ្យតំហែទាំសុខភាពរបស់មនុស្សនោះដោយផ្ទាល់បានទេ។

យើងខ្ញុំចង់ស្តាប់ឮពីអ្នក! បន្ទាប់ពីការអានទំព័រព័ត៌មានសំខាន់ៗនេះ សូមចូលរួមធ្វើអង្កេត ឬ កិច្ចសម្ភាសន៍ខ្លីនេះ ហើយផ្តល់មតិយោបល់ ឬ លទ្ធផលត្រឡប់របស់អ្នកមកយើងខ្ញុំវិញ។

សំណៅបកប្រែជាភាសាអង់គ្លេស: http://fs12.formsite.com/disabilityrightsca/form54/index.html

សំណៅបកប្រែជាភាសាអេស្ប៉ាញ: http://fs12.formsite.com/disabilityrightsca/form55/index.html

*កម្មវិធីគ្រប់គ្រងស្លាកស្នាមខុយស, កាត់បន្ថយបញ្ហាការរើសអើង, និង អនុវត្តគោលការណ៍ផ្សព្វផ្សាយបំបាត់បញ្ហាការរើសអើង (APEDP) ទទួលបានការឧបត្ថម្ភថវិកាតាមរយៈច្បាប់ស្តីពីសេវាកម្មសុខភាពផ្លូវចិត្ត ដែលទទួលបានការបញ្ជាក់យល់ព្រមដោយការបោះឆ្នោត (Prop. 63) និង មានការគ្រប់គ្រងដោយអាជ្ញាធរទទួលបន្ទុកសុខភាពផ្លូវចិត្តនៃរដ្ឋកាលីហ្វ័រញ៉ា (CalMHSA)។ មូលនិធិ MHSA តំបន់ ឬ ខោនធី គាំទ្រដល់ CalMHSA ដែលជាអង្គការមួយរបស់រដ្ឋាភិបាលតំបន់នានា ដែលធ្វើការលើកកម្ពស់លទ្ធផលសុខភាពផ្លូវចិត្តសម្រាប់បុគ្គល ក្រុមគ្រួសារ និង សហគមន៍នានា។ CalMHSA ធ្វើប្រតិបត្តិការផ្តល់សេវាកម្ម និង កម្មវិធីអប់រំនានានៅទូទាំងរដ្ឋ តាមតំបន់ និង មូលដ្ឋាននានា។ ដើម្បីស្វែងយល់ព័ត៌មានច្រើនទៀត ចូរមើលវិបសាយ http://www.calmhsa.org។*